ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## លោក JOHN R.W.D. JONES ត្រូវបានចាត់តាំងជាសហមេធាវីការពារក្តីអន្តរជាតិ ដើម្បីតំណាងជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង 004

អង្គភាពគាំពារការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានចាត់តាំងលោក **John R.W.D. Jones** ជនជាតិអង់គ្លេស ជាសហមេធាវីអន្តរជាតិ ដើម្បីតំណាងជនសង្ស័យម្នាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី គឺជាផ្នែកមួយនៃសំណុំរឿង ០០៤។ អត្តសញ្ញាណនៃជនសង្ស័យណាម្នាក់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីនេះ នៅតែរក្សាការសម្ងាត់ដដែល។

លោកគឺជាមេធាវីការពារក្តីដែលមានការិយាល័យនៅទីក្រុងឡុងដ៍ ជំនាញខាងឧក្រិដ្ឋកម្មសង្គ្រាម ការប្រឆាំងភេរវកម្ម និងបញ្ហាការធ្វើបត្យាប័ន។ លោកត្រូវបានទទួលការអនុញ្ញាតឲ្យអនុវត្តវិជ្ជាជីវៈច្បាប់នៅចំពោះមុខតុលាការនៅប្រទេសអង់គ្លេសនិងវែលស៍ ខណ្ឌកូឡុំប៊ីនៃសហរដ្ឋអាមេរិក និង នៅព្រះរាជាណាចក្រកម្ពុជា ។ លោកបានការពារក្តីក្នុងសំណុំរឿងឧក្រិដ្ឋកម្មសង្គ្រាម៥ផ្សេងៗគ្នា (ករណី *Mehmed Alagic, Naser Oric, Momcilo Krajisnik, Rasim Delic* និងករណី *Mladen Markac*)។ លោកបានធ្វើការនៅសាលាក្តី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសំខាន់ៗរួមមាន តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា តុលាការពិសេសសម្រាប់ប្រទេស សៀរ៉ាឡេអូន តុលាការពិសេសសម្រាប់ប្រទេសលីបង់ និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ បច្ចុប្បន្ននេះ លោកការពារកូនក្តីឈ្មោះ Saif Gaddafi នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។ លោកបានបោះពុម្ពផ្សាយសៀវភៅជាច្រើនក្បាល និងធ្វើបទបង្ហាញយ៉ាងច្រើនអំពីច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម



Original EN:

ព្រមទាំងជាសហនិពន្ធសៀវភៅដែលមានចំណងជើងថា “**ទម្លាប់អនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ**” ។ លោកបានផ្តល់ប្រឹក្សាដល់អាជ្ញាធររដ្ឋាភិបាល និងអង្គការអន្តរជាតិនានាអំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាម ហើយថែមទាំងបានបង្រៀននីតិព្រហ្មទណ្ឌអន្តរជាតិនៅមហាវិទ្យាល័យ London School of Economics ទៀតផង។

លោក **John R.W.D. Jones** នឹងធ្វើការជាមួយលោក **ប៊ិត ស៊ាងលីម** ដែលត្រូវបានចាត់តាំងជាសហមេធាវីជាតិតំណាងឲ្យជនសង្ស័យដូចគ្នានេះ។ មុននឹងធ្វើការចាត់តាំងទាំងនេះ អង្គភាពគាំពារការការពារក្តី បានពិចារណាដោយផ្អែកលើការចង់បានរបស់ជនសង្ស័យ និងរាល់ការលះបង់សិទ្ធិទាំងអស់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ។

សម្រាប់ព័ត៏មានបន្ថែម សូមទាក់ទង៖


លោក ឡាស អលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh




Original EN: